ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានពន្ធដារ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ភ្នំពេញ ថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៧

# សេចក្តីប្រកាសព័ត៌មាន

## ស្តីពី

## ការទទួលជួបពិភាក្សាជាមួយប្រតិភូ IMF (International Monetary Fund) អំពីវឌ្ឍនភាព នៃការអនុវត្តយុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨ (RMS)

### អគ្គនាយកដ្ឋានពន្ធដារ ថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៧


© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ


© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ

នាវេលាម៉ោង ៩ព្រឹក ថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៧ នៅសាលប្រជុំ នៃអគ្គនាយកដ្ឋានពន្ធដារ **ឯកឧត្តម គង់ វិបុល** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ បានទទួលជួបពិភាក្សាជាមួយប្រតិភូ **IMF (International Monetary Fund)** ដឹកនាំដោយលោកស្រី **Debra ADAM** ដើម្បីពិភាក្សាអំពីវឌ្ឍនភាពនៃការអនុវត្តយុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨ ដោយមានការចូលរួមពី ឯកឧត្តមអគ្គនាយករង ថ្នាក់ដឹកនាំគ្រប់ជាន់ថ្នាក់ និងមន្ត្រីពាក់ព័ន្ធនៃអគ្គនាយកដ្ឋានពន្ធដារ។

ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល បានពន្យល់បង្ហាញដល់ប្រតិភូ IMF ថា ស្របតាមគោលនយោបាយកែទម្រង់ស៊ីជម្រៅរបស់រាជរដ្ឋាភិបាល អគ្គនាយកដ្ឋានពន្ធដារបានខិតខំប្រឹងប្រែងអនុវត្តសកម្មភាពកែទម្រង់ ជាពិសេសការខិតខំអនុវត្តយ៉ាងម៉ឺងម៉ាត់ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងការអនុវត្តយុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨ (RMS)។ ជាលទ្ធផល អគ្គនាយកដ្ឋានពន្ធដារ សម្រេចបាននូវវឌ្ឍនភាព និងសមិទ្ធិផលសំខាន់ៗជាច្រើន ជាពិសេសកំណើនចំណូលពន្ធចាប់តាំងពីឆ្នាំ២០១២គឺតែងតែសម្រេចបានលើសផែនការ ហើយការប្រមូលចំណូលពន្ធ បានកើនឡើងជាមធ្យមប្រមាណ ២០% ក្នុងមួយឆ្នាំ ដែលជាក់ស្តែងបានកើនប្រមាណពី ៧៥៩ លានដុល្លារអាមេរិក ក្នុងឆ្នាំ២០១២ រហូតទទួលបានប្រមាណជាង ១,៥ ពាន់លានដុល្លារអាមេរិក ក្នុងឆ្នាំ២០១៦។ ដោយឡែកសម្រាប់ត្រីមាសទី ១ ឆ្នាំ២០១៧ សម្រេចបានដល់ទៅប្រមាណជាង ៧៦៨លានដុល្លារអាមេរិក



© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ



© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ

ស្មើនឹង ៤៥% នៃផែនការកំណត់ដោយច្បាប់។

លោកស្រី **Debra ADAM** ប្រធានប្រតិភូ IMF បានបង្ហាញនូវចំណាប់អារម្មណ៍ វាយតម្លៃខ្ពស់ និងកោតសរសើរចំពោះវឌ្ឍនភាព ជាពិសេសលទ្ធផលជាវិជ្ជមាន និងល្អប្រសើរ ដែលកើតចេញពីកិច្ចខិតខំអនុវត្តយ៉ាងម៉ឺងម៉ាត់ចំពោះកម្មវិធីកែទម្រង់នានា ទាំងផ្នែកគោលនយោបាយ និងផ្នែករដ្ឋបាលសារពើពន្ធ របស់អគ្គនាយកដ្ឋានពន្ធដារ ជាពិសេសការធ្វើទំនើបកម្មព័ត៌មានវិទ្យា និង ការអនុវត្តយុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨ កន្លងមក ដែលទាំងនេះបានសបញ្ជាក់នូវភាពរីកចំរើននៃការគ្រប់គ្រងប្រមូលចំណូលពន្ធ ប្រកបដោយតម្លាភាព សុច្ចរិតភាព ប្រសិទ្ធភាព និងសក្តិសិទ្ធភាព ៕



© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ



© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ



© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ



© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ